# ស្ពាន នៃសាសនា

១. ព្រះពុទ្ធ បុគ្គល់ យល់ជ្រៅជ្រះ
បញ្ញាតេជះ សែនផូផង់
ល្អិតល្អន់របរវ ល្អទ្រើបទ្រង់
ជាផ្លូវតំរង់ អោយខេមរា ។
២. សាសនា ព្រះពុទ្ធ ពិតជាផ្លូវ
អោយប្រព្រឹត្តិត្រូវ តាមបញ្ញា
សាងបុណ្យកុសល្យ តាមជ្រះថ្លា
មិនមែនហ៊ឹហា តាមចំណង់ ។
៣. ទ្រឹស្តីប្រកបដោយ វិទ្យា
ជាស្ពានបញ្ញា ឆ្ពោះតំរង់
ដាស់តឿនសតិ អោយផូផង់
ដើរតាមផ្លូវត្រង់ បង់ផ្លូវវេ ។
៤. តែអកុសល្យ ផលជីវិត
អ្នកប្រាជ្ញបណ្ឌិត នៃជាតិខ្មែរ
ពូកែខាងឆ្វៃ ន័យអោយវេ
វាចាក់បុព្វេ ពីវិទ្យា ។
៥. យកពាក្យកម្មផល មកបន្ទាច
អោយខ្មែរខ្លបខ្លាច នឹងកម្មពៀរ
បាក់អស់ស្មារតី ខ្មែររាល់គ្នា
កើតរោគស្មុក់ស្មារ ក្នុងជីវិត ។
៦. ជាតិមុខ ជាតិក្រោយ មានពីណា
នោះសុទ្ធវោហា គ្មានការពិត
ការបកស្រាយខុស អស់បណ្ឌិត
ដែលមិនចេះគិត ស៊ីរាក់ជ្រៅ ។
៧. ព្រះពុទ្ធឱវាទ មានន័យសម
ត្រូវនិងសង្គម មិនមែនខ្លៅ
មកស្រាយន័យខុស ចាកពីផ្លូវ
ព្រោះតែតំរូវ ពាក្យកម្មពៀរ ។
៨. ជាតិមុនព្រះពុទ្ធ មានន័យផ្សេង
នោះគឺវ័យក្មេង ជាកុមារ
ដែលច្បាប់សង្គម តំរូវថា
មាតា បិតា ជាតំណាង ។
៩. ទទួលខុសត្រូវ សព្វសារពើ
ដែលបុត្របានធ្វើ និងបានសាង
ល្អ ឬអាក្រក់ ជាសំណាង
ដែលខ្លួនបានសាង នឹងអោយផល ។
១០. ទៅដល់មជ្ឈិម វ័យកណ្តាល
ដែលត្រូវទទួល នូវកុសល្យ
ជាបុណ្យ ឬបាប តាមដែលផល
ដែលខ្លួនតំដល់ ពីកុមារ ។

១១. នេះហើយគឺជា បច្ចុប្បន្នជាតិ នៅក្នុងឱវាទ ពុទ្ធសាសនា
រីឯជាតិមុខ នោះគឺជា វ័យចាស់ជរា នៃមនុស្សយើង ។

១២. ព្រះពុទ្ធគឺជា លោកវិទូ មិនមែនជាគ្រូ ព្រហ្មដង្ហើង
សូត្រមន្តអាគម គាស់រំលើង ស្រោចទឹកដំកើង រាសីទេ ។

១៣. មានសង្ឃ អាចារ្យ ខ្លះសព្វថ្ងៃ យកធម៌ព្រះត្រៃ មកបកប្រែ
ខុសពីន័យដើម ជាហូរហែរ នាំអោយជាតិខ្មែរ ធ្លាក់ហន្តរាយ ។

១៤. សង្ឃ និងអាចារ្យ នោះចាចោរ ដើរទេស ដើរប្រូ ព្រោះសប្បាយ
ដើបោកយកប្រាក់ យកទៅចាយ សូកសង្ឃចៅហ្វាយ យកថានៈ ។

១៥. បើបួសជាសង្ឃ ឬអាចារ្យ សួរថា ហ៊ឺហា អីនិងប្រាក់?
ចង់បានធ្វើអី បុណ្យថានៈ? ម្តេចមិនគិត ជាក់មុនសំរេច?

១៦. បួសយកសាសនា ធ្វើជាស្ពាន ដើម្បីធ្វើមាន ធ្វើជាស្តេច
ពេលមានឱកាស់ បានសំរេច សឹកលាធ្វើស្តេច ឬមន្ត្រី ។

១៧. អាចារ្យស្បៀកស តែចិត្តខ្មៅ គំនិតក៏ខ្មៅ គិតក៏ខ្វី
តាំងខ្លួនអ្នកចេះ ធម៌វិន័យ តាមពិតសត្វព្រៃ មិនស្គាល់ដឹង ។

ដោយ **សួន សេរីរដ្ឋា**

បាត់ដំបង កម្ពុជា ១១ វិច្ឆកា ២០០៤